# ពត៌មានសំខាន់អំពីកិច្ចព្រមព្រៀងនេះ

## 1. លោកអ្នកត្រូវតែធ្វើការប្រឹងប្រែងដោយស្មោះត្រង់ដើម្បីលក់ទ្រព្យសម្បត្តិនៅក្រោមលក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះ ។

នៅពេលដែលលោកអ្នកចុះហត្ថលេខានៅលើសន្លឹកម្ខាងទៀតនៃសំណៅនេះ លោកអ្នកយល់ព្រមចាប់ផ្តើមវិធានការចាប់តាំងពីឥឡូវនេះដើម្បីលក់ទ្រព្យសម្បត្តិរបស់លោកអ្នក និង បន្តការប្រឹងប្រែងដោយស្មោះត្រង់ដើម្បីលក់ទ្រព្យសម្បត្តិរហូតទាល់តែទ្រព្យសម្បត្តិនោះលក់ដាច់ ឬរហូតទាល់តែធនធានរបស់លោកអ្នកលែងមានចំនួនច្រើនជាងចំនួនដែលគ្រួសារអាចមាន និងអាចនៅទទួលប្រាក់ជំនួយ ។ ដើម្បីធ្វើការប្រឹងប្រែងដោយស្មោះត្រង់ដើម្បីលក់ទ្រព្យសម្បត្តិ យ៉ាងហោចណាស់ លោកអ្នកត្រូវអនុវត្តតាមខណាមួយដូចខាងក្រោមនេះ :

a) ចុះទ្រព្យសម្បត្តិដាក់លក់ជាមួយអ្នកលក់ទ្រព្យសម្បត្តិជាអចលនវត្ថុដែលមានច្បាប់អនុញ្ញាត និងយល់ព្រមចរចាតម្លៃ និងលក្ខខ័ណ្ឌនៃការលក់ដូរជាមួយអ្នកណាដែលអាចជាអ្នកទិញ ឬ

b) ធ្វើការប្រឹងប្រែងដោយផ្ទាល់ខ្លួនដើម្បីលក់ទ្រព្យសម្បត្តិដោយត្រូវតែមានបញ្ចូលលលក្ខណៈដូចតទៅនេះ :

- ដាក់ផ្សាយលក់មួយសប្តាហ៍ម្តងយ៉ាងហោចណាស់នៅក្នុងសារពត៌មានចេញផ្សាយជាទូទៅមួយ ថាទ្រព្យសម្បត្តិសំរាប់លក់ ។ លោកអ្នកអាចបញ្ឈប់ការប្រកាសផ្សាយលក់ ឬឈប់ចំណាយប្រាក់ដើម្បីលក់ទ្រព្យសម្បត្តិនេះ នៅពេលណាដែលធនធានរបស់លោកអ្នកលែងមានចំនួនច្រើនជាងចំនួនដែលគ្រួសារអាចមានហើយអាចនៅទទួលប្រាក់ជំនួយ ។
- ដាក់ផ្លាកលក់នៅលើទ្រព្យសម្បត្តិបង្ហាញថា ទ្រព្យសម្បត្តិសំរាប់លក់ ។ នៅពេលដែលអាចធ្វើបាន ផ្លាកលក់ត្រូវតែអាចមើលឃើញពីផ្លូវថ្នល់ ។
- ត្រូវស្ម័គ្រចិត្តចរចាអំពីតម្លៃនិងលក្ខខ័ណ្ឌលក់ជាមួយអ្នកណាដែលអាចជាអ្នកទិញ និងឆ្លើយតបទៅនឹងការសាកសួរសមហេតុផលទាំងអស់អំពីទ្រព្យសម្បត្តិ ។

## 2. លោកអ្នកត្រូវព្យាយាមលក់ទ្រព្យសម្បត្តិដោយមិនឱ្យមានតម្លៃថ្លៃជាងតម្លៃលក់ត្រឹមត្រូវតាមទីផ្សារ ។

តម្លៃលក់តាមទីផ្សារសមរម្យនៃទ្រព្យសម្បត្តិគឺជាការជ្រើសរើសរបស់លោកអ្នក នៃ :

- តម្លៃប៉ាន់ស្មាននៃទ្រព្យសម្បត្តិ ឬ
- ការប៉ាន់តម្លៃនៃទ្រព្យសម្បត្តិតាមទីផ្សារដែលបានទទួលដោយលោកអ្នកពីអ្នកលក់អចលនវត្ថុដែលមានច្បាប់អនុញ្ញាត ។

ខណ្ឌនិងលោកអ្នកអាចយល់ព្រមនៅលើតម្លៃតាមទីផ្សារដោយយោងទៅតាមពត៌មានដទៃទៀតដែលអាចមាន នៅពេលណា :

a) ទ្រព្យសម្បត្តិនៅក្នុងតំបន់ដាច់ស្រយាល និង

b) គឺជាការមិនអាចធ្វើទៅបាន ឬធ្វើមិនកើតដើម្បីទទួលនូវតម្លៃនៃទ្រព្យសម្បត្តិ និង

c) លោកអ្នកជឿថា តម្លៃដែលបានប៉ាន់គឺថ្លៃឬថោកពេក ។

## 3. សូមប្រាប់ក្រសួងសុខុមាលភាពនៃខណ្ឌរបស់លោកអ្នក នៅពេលណា :

- លោកអ្នកលក់ទ្រព្យសម្បត្តិ ឬ
- លោកអ្នកមានបញ្ហាក្នុងការលក់ទ្រព្យសម្បត្តិ ឬ
- លោកអ្នកសំរេចថាមិនលក់ទ្រព្យសម្បត្តិ ។

☐ លោកអ្នកអាចជួបទាក់ទងទៅខណ្ឌនៅ ______________________________ ដើម្បីសាកសួរថាតើលោកអ្នកត្រូវតែបន្តចំណាយប្រាក់ដើម្បីលក់ទ្រព្យសម្បត្តិនេះឬទេ ។

# កិច្ចព្រមព្រៀងដើម្បីលក់ទ្រព្យសម្បត្តិ

**សំគាល់** : សូមភ្ជាប់មកជាមួយនូវសេចក្តីចម្លងនៃឯកសារធនធានដទៃទៀតដែលមានក្រុមគ្រួសារជាម្ចាស់នៅក្នុងពេលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ (ជាឧទាហរណ៍ សេចក្តីថ្លែងការ ពត៌មានគាំទ្រនូវភាពអាចមានសិទ្ធិទទួលជំនួយ) ។

| ឈ្មោះ | | ឈ្មោះប្តីឬប្រពន្ធ | | |
|---|---|---|---|---|
| លេខសំណុំរឿង | លេខសន្និច្ច័យសង្គ្រោះ<br>— — | លេខបណ្ណបើកបរ *(សូមចុះឈ្មោះរដ្ឋ)* | | |
| អាសយដ្ឋាន ឬទីកន្លែងនៃទ្រព្យសម្បត្តិអចលនវត្ថុ | ឈ្មោះម្ចាស់ | ការប្រមាណតម្លៃនៅក្នុងពេលបច្ចុប្បន្ន | ចំនួនដែលបានជំពាក់(ប្រាក់ខ្ចី ប្រាក់បញ្ចាំ សំបុត្រជំពាក់ បំណុលដទៃទៀត | ការប្រមាណនៃប្រាក់ទទួលសុទ្ធបានមកពីលក់ |
| | | | | |
| | | | | |

## លក្ខខណ្ឌនៃកិច្ចព្រមព្រៀង

យើង/ខ្ញុំយល់ថា ធនធានរបស់យើង/ខ្ញុំដោយគិតបញ្ចូលទាំងទ្រព្យសម្បត្តិជាអចលនវត្ថុដូចបានចុះនៅខាងលើ គឺមានចំនួនច្រើនជាងចំនួនដែលគ្រួសារអាចមានហើយនៅទទួលប្រាក់ជំនួយនៅក្រោមកម្មវិធីជួយឱ្យធ្វើការនិងទទួលខុសត្រូវចំពោះកូននៃរដ្ឋកាលីហ្វរ័នីញ៉ា (California Work Opportunity and Responsibility to Kids ឬ CalWORKS) ។ យើង/ខ្ញុំសុំសំណូមពរឱ្យគេបង់ប្រាក់ជំនួយមកឱ្យយើង/ខ្ញុំ រហូតទាល់តែពេលដែលយើង/ខ្ញុំអាចលក់ទ្រព្យសម្បត្តិជាអចលនវត្ថុដូចមានចុះនៅខាងលើទៅតាមតម្លៃលក់ទីផ្សារដ៏សមរម្យ ។ យើង/ខ្ញុំយល់ព្រមអនុវត្តនូវវិធានការជាចាំបាច់និងត្រឹមត្រូវដើម្បីលក់ទ្រព្យសម្បត្តិអចលនវត្ថុនេះ និងបន្តនូវការប្រឹងប្រែងរបស់យើង/ខ្ញុំយ៉ាងសកម្មធ្វើដូច្នេះរហូតទាល់តែទ្រព្យសម្បត្តិលក់ដាច់ ឬក៏ទាល់តែធនធានរបស់យើង/ខ្ញុំលែងមានចំនួនច្រើនជាងចំនួនដែលគ្រួសារអាចមាន និងនៅតែទទួលប្រាក់ជំនួយ ។ យើង/ខ្ញុំយល់ថា យើង/ខ្ញុំមានរយៈពេលប្រាំបួន(៩)ខែដើម្បីលក់ទ្រព្យសម្បត្តិ ។ យើង/ខ្ញុំយល់ថា បើសិនជាទ្រព្យសម្បត្តិលក់មិនដាច់នៅពេលបញ្ចប់៩ខែ និងធនធានរបស់យើង/ខ្ញុំនៅតែមានចំនួនលើសចំនួនបានអនុញ្ញាត យើង/ខ្ញុំនិងមិនមានសិទ្ធិទទួលប្រាក់ជំនួយនៅក្រោមកម្មវិធី CalWORKs ឡើយ ។ យើង/ខ្ញុំក៏យល់ផងដែរថា យើង/ខ្ញុំនឹងត្រូវបង់សងចំនួនប្រាក់ជំនួយដែលយើង/ខ្ញុំទទួលដែលមិនគួរត្រូវបានទទួល បើសិនជាយើង/ខ្ញុំបានលក់ទ្រព្យសម្បត្តិនៅថ្ងៃដែលប្រាក់ជំនួយត្រូវបានផ្តល់ឱ្យនៅក្រោមលក្ខខណ្ឌទាំងនេះ ។

| | | | |
|---|---|---|---|
| ហត្ថលេខាឬគំនូសសំគាល់នៃអ្នកដាក់ពាក្យសុំ/អ្នកទទួល | អាសយដ្ឋានបច្ចុប្បន្ន | ក្រុង រដ្ឋ លេខហ្ស៊ីបកូដ | កាលបរិច្ឆេទ |
| ហត្ថលេខាឬគំនូសសំគាល់នៃប្តីប្រពន្ធ | អាសយដ្ឋានបច្ចុប្បន្ន | ក្រុង រដ្ឋ លេខហ្ស៊ីបកូដ | កាលបរិច្ឆេទ |
| ហត្ថលេខាឬគំនូសសំគាល់នៃសាក្សី | អាសយដ្ឋានបច្ចុប្បន្ន | ក្រុង រដ្ឋ លេខហ្ស៊ីបកូដ | កាលបរិច្ឆេទ |

បទបញ្ញត្តិ : ច្បាប់សុខុមាលភាពនិងស្ថាប័នលេខ 11257.5, MPP 42-213.12

លេខសន្និច្ច័យសង្គ្រោះ : លេខនេះនឹងយកមកប្រើនៅក្នុងការិយាល័យចាត់ការនៃកម្មវិធី CalWORKs និងនៅពេលដែលសម្របសម្រួលពត៌មានជាមួយក្រសួងសាធារណៈដទៃទៀត ។